**ប្រការ ៣** : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

**ប្រការ ៤** : ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍នៃអគ្គនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ និងប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៥** : ប្រកាសនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ខៀវ កាញារីទ្ធ**

* * *

## ២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ_យុវជន និងកីឡា

## ប្រកាស

ភ្នំពេញ , ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៩៦

**ប្រកាសលេខ : ៤៣០ អយក.ប្រក**

**ស្ដីពីការប្ដូរឈ្មោះ អនុវិទ្យាល័យ មហាសៀក ទៅជា**

**« អនុវិទ្យាល័យមហាមង្គល ហ៊ុន សែន »ស្ថិតនៅក្នុង**

**ឃុំមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម**

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេច **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤
- បានឃើញក្រឹត្យ ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធ អប់រំចំណេះទូទៅ
- យោងលិខិតរបស់គណៈកម្មការសមាគមមាតាបិតាសិស្ស អនុវិទ្យាល័យមហាសៀក ចុះថ្ងៃទី ០១ ឧសភា ១៩៩៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាលខេត្តកំពង់ចាម
- តាមយោបល់ឯកភាពរបស់ឯកឧត្តមរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និង កីឡា ។

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យមហាសៀកបច្ចុប្បន្នទៅជា «អនុវិទ្យាល័យមហាមង្គល **ហ៊ុន សែន**» ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ តទៅ ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និង កីឡា ប្រធានមន្ទីរអប់រំយុវជន និង កីឡា ខេត្តកំពង់ចាម និង នាយក អនុវិទ្យាល័យមហាមង្គល **ហ៊ុន សែន** មានភារកិច្ចរៀង ៗ ខ្លួនអនុវត្តប្រកាសនេះ ។

ជ-រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា
រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
**គា សាឃាន**

* * *